# ពិភពរឿងនិទាន

The World of Stories



# ភ្នំបាយ៉ង់កោរ

# Bayong Kor Mountain

សៀវភៅជាឃ្លាំងនៃចំណេះដឹង

Books are the source of knowledge

ជាយូរលង់ណាស់មកហើយ នៅប្រទេសខ្មែរមានស្តេចមួយអង្គ ទ្រង់ព្រះនាម **ព្រះបាទបាយ៉ង់** មានព្រះរាជដំណាក់នៅលើភ្នំដងរែក មានព្រះអគ្គមហេសីព្រះនាម **នាងសក់ក្រអូប** ប្រកបដោយព្រះរូបឆោម ព្រះភក្ត្រល្អប្រិមប្រិយ សម្បុរភ្លឺថ្លាដូចនាងទេពធីតា ក្លិនក្រអូបសាយចេញជុំវិញព្រះកាយមួយយោជន៍ កិត្តិយសល្បីសុសសាយទៅដល់ព្រះចៅសៀម។



ស្តេចសៀមក៏ចាត់មនុស្សមកស៊ើបអង្កេត បានដឹងពិតប្រាកដថា ព្រះនាងជាម្ចាស់ក្សត្រីយ៍ដ៏ស្រស់ស្អាត ជាស្រីបរិបូរណ៍ដោយលក្ខណៈល្អគ្រប់យ៉ាង។ ស្តេចសៀមក៏រកឧបាយកលចូលមកចាប់ព្រះនាងយកទៅដើម្បីជាកិត្តិយសប្រទេសខ្លួន។ **ស្តេចបាយ៉ង់** ទ្រង់ជ្រាបការណ៍ដូច្នេះ ក៏នាំព្រះមហេសី ពួកស្រីស្នំក្រមការ និងពលសេនាទាំងអស់ចុះសំពៅ ភៀសព្រះនាងយាងចេញចោលដំណាក់ទាំងយប់ បើកសំពៅទៅទិសអាគ្នេយ៍។ មុននឹងយាងចេញ ទ្រង់លើកព្រះហស្តប្រណម្យដាក់លើព្រះសិរសា សច្ចាបន់ទេវតារក្សាទឹកថា "សូមឱ្យសម្រេចសេចក្តីប្រាថ្នាបីប្រការគឺ ៖

១-សូមឱ្យបានសុខក្នុងដំណើរផ្លូវសាគរ

២-សូមកុំឱ្យពួកចោរសៀមតាមទាន់

៣-សូមឱ្យបានជួបប្រទះកន្លែងជាទីគាប់ចិត្ត។ បើបានសម្រេចដូចបំណង នឹងកោរសក់ថ្វាយ"។

Long time ago, in Khmer kingdom there was a king named Preah Bat Bayong, who had a royal palace in Dangrek Mountain. The king had a wife named Neang Sak Kraob. She was the most beautiful woman with smiling face, and white complexion like an angel. The good fragrance of her body could be smelled around 16 kilometers. Then, this great fame was publicized to Siam king. This king sent a spy to find out and finally they knew that the queen was really a beautiful and faithful woman. The Siam king made a bad scheme to catch her to his kingdom for the great honor of his country. When Preah Bat Bayong knew this trick, he immediately took his wife, group of ladies- in- waiting, servants, officers and all soldiers to leave the palace by ithe junks toward the southeast in the nighttime. Before leaving, the king raised his both hands on the head and prayed to God, "May I achieve three wishes

1. Have a safe journey on the waterway,
2. Be not caught up by Siam soldiers
3.Find a good residence. If the three wishes become true, I will have my hair shaved as devotion."

ស្តេចទ្រង់ព្រួយព្រះទ័យជាខ្លាំង ទ្រង់បើកសំពៅទាំងយប់ទាំងថ្ងៃ។ លុះទ្រង់ប្រមើលមើលឃើញថា ចេញមកបានឆ្ងាយណាស់មកហើយ ទើបទ្រង់ងាកវេទៅរកតំបន់មួយដើម្បីចតសំពៅ។ ជួនជាពេលនោះខ្យល់ព្យុះបក់បោកសំពៅឱ្យវិលវល់បាក់ចង្កូត។ ទើបនៅទីនោះមានឈ្មោះថា "ភូមិបាក់ចង្កូត" ដែលសព្វថ្ងៃគេហៅក្លាយមកជា "ភូមិបាក់កូត"។ ស្តេចទ្រង់ភ័យហើយលើកព្រះហស្តអំពាវនាវបន់ថា "សូមឱ្យបាត់ព្យុះទាំងនេះទៅ នឹងសែនថ្វាយដល់ពួកអារក្សទឹកទាំងឡាយ"។ គ្រានោះ ខ្យល់ព្យុះក៏ស្ងប់ស្ងាត់អស់មួយរំពេច។ លុះទៅបានបន្តិចទៀតក៏ឈប់បោះយុថ្កាចត ទើបនៅទីនោះមានឈ្មោះថា "ភូមិកន្លែងចត"។ ការឈប់ចតនេះ គឺដើម្បីរៀបចំនំចំណីអាហារសែនថ្វាយអារក្សទឹក និងធ្វើចង្កូតសំពៅជាថ្មី។ ត្រង់តំបន់ដែលថ្វាយអាហារនោះ នៅមានឈ្មោះជាប់មកដល់សព្វថ្ងៃថា "ភូមិសែនបន់"។ ទាំងបីកន្លែងនេះ នៅឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។ លុះសម្រេចកិច្ចនៅកន្លែងនោះសព្វគ្រប់ហើយ ទ្រង់ក៏យាងចេញសំពៅទៅទៀតសំដៅទៅទិសអាគ្នេយ៍ដដែល។



The king was so worried that he sailed the junk day and night. When he discovered that he had been so far, the king looked for a place to land the junk. At the same time,the storm blew the junk to move round and broke its wheel. That was the reason why this place has been called "Bak Changkot village" (village where junk broke its wheel), but nowadays this village is known as "Bakkot village". The king was very frightened so he raised his hands and prayed, "May the storm vanish; and I will deliver the offerings for the water demons." Suddenly, the storm disappeared. After sailing a bit further, the king anchored the junk, prepared the offerings for the water demons, and made a new wheel of the junk. That place has been called "Kanleng Chot village" (village where the king anchored the junk) and the place, where the offerings were

delivered to the water demons, has been called "Senbon village" nowadays. The three mentioned villages are located in Leay Bor commune, Tram Kok district, Takeo province. After finishing all work there, the king continued his journey in the same direction toward the southeast.



លុះទៅដល់កន្លែងមួយ សំពៅក៏ធ្លាយទ្រង់ចាប់ផ្តើមធ្វើសំពៅបណ្តើរបើកទៅមុខបណ្តើរ។ ត្រង់កន្លែងនោះជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃថា "សំពៅធ្លាយ"។ បើកបន្តិចទៅទៀតដល់កន្លែងមួយឃើញដីមានដុះស្បូវច្រើន ក៏បោចស្បូវនោះមកចុកសំពៅដែលធ្លាយ។ ត្រង់កន្លែងនោះជាប់ឈ្មោះមកដល់សព្វថ្ងៃថា "ភូមិព្រៃកស្បូវ" ហើយបើកសំពៅធ្វើដំណើរតទៅទៀតដល់កន្លែងមួយ **ព្រះនាងសក់ក្រអូប** ទ្រង់កើតទុក្ខព្រួយព្រះទ័យច្រើនប្រការ ណាមួយអំពីការធ្វើដំណើរដែលចេះតែឆ្ងាយទៅៗរកទីសំណាក់មិនឃើញ ម្យ៉ាងទៀតអំពីពួកសៀមថាមុខជាគេតាមទាន់មិនខាន។ ព្រះនាងទ្រង់អុជទៀននមស្ការបន់ស្រន់ ដល់អារក្សទឹក អារក្សគោក និង អ្នកតាព្រៃភ្នំក្រមថ្មសព្វទីកន្លែងថា "សូមឱ្យបានជួបកន្លែងសុខប្រសើរ សូមឱ្យចោរសៀមចិត្តអប្រិយបរាជ័យវិនាសក្នុងសាគរ"។



ត្រង់កន្លែងដែលព្រះនាងអុជទៀនបន់នោះ ជាប់ឈ្មោះរហូតមកដល់សព្វថ្ងៃហៅថា "ភូមិអន្លង់ទៀន"។ ពិធីនមស្ការអំពាវនាវរបស់ព្រះនាងនោះបានសម្រេចដូចសេចក្តីប្រាថ្នាមែន គឺសំពៅស្តេចសៀមដែលបានបញ្ជូនពលចំនួនមួយសែននាក់ កំពុងតាមស្កាត់រកព្រះនាងនោះ ក៏ជ្រួសផ្លូវគ្នា ដោយសំពៅ **ស្តេចបាយ៉ង់** ចេញទៅផ្នែកខាងកើត សំពៅពួកពលសៀមចេញទៅផ្នែកខាងលិច។ ក្រោយដែលព្រះនាងបន់ស្រន់រួចហើយ សំពៅ **ស្តេចបាយ៉ង់** ក៏ងាកសំដៅទៅទិសនិរតីបន្តិច។ បន្ទាប់ពីនោះ ស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំងបក់បោកសំពៅសៀមខ្ទេចខ្ទីលិចលង់ស្លាប់អស់ពួកពលនៅក្នុងមហាសាគរ។ ត្រង់កន្លែងនោះមានឈ្មោះថា "ភូមិសែនលង់" ជាប់រហូតមកដល់សព្វថ្ងៃ គេហៅក្លាយមកជា "ភូមិសន្លុង" វិញ។

When he arrived at a place, the junk was leaked so the king was repairing while sailing. That place has been named "Sampov Threay village" up to now (where the junk had a leak). Traveling further, he arrived at a place where there were many thatches growing. The king pulled out the thatches and inserted them into the leak. Since then, this place has been known as "Prek Sbov village" (where there were many thatches growing). Then, they continued their journey. When they reached a place, Qween Sak Kraob was worried about many things, one was that the journey was further and further and the target was not found yet and another thing that she was afraid was that Siam soldiers might catch up with them. Then, the Queen lit the candles in order to pray to the all demons, "May we find a safe, good residence and May cruel Siam soldiers fail and be damaged in the ocean." The place, where the queen lit the candles to pray to the demons, has been called "Anlong Tien village". The praying ceremony made her wish come true. 100 thousand Siam soldiers that the Siam King sent to chase her missed her way. They sailed their junk to different directions. The king Bayong's junk departed to the east, while Siam Junk went to the west. After the Queen prayed, the king Bayong turned his junk a bit to the southwest. Then suddenly, there was a storm to blow and damage Siam junk and all the soldiers were drowned to death in the ocean. The place where Siam junk was damage by the storm had been named "Senlong village". Today this village has been changed to "Sanlong village".

ចំណែកសំពៅ **ស្តេចបាយ៉ង់** កាលបើលឿនត្រង់ទៅទិសនិរតី ទ្រង់ទតឃើញកោះ និងភ្នំជាច្រើន ព្រះអង្គក៏ចូលទៅបោះយុថ្កាចតសំពៅនៅក្បែរកោះមួយ ស្តេចយាងឡើងលើកោះនោះដើម្បីរកទីកន្លែងដ៏សមគួរនឹងអាចរស់នៅបណ្តោះអាសន្នបាន ព្រះអង្គទតឃើញកន្លែងល្អៗជាច្រើនដែលគាប់ព្រះទ័យ ក៏ឱ្យពួកពលជញ្ជូនអីវ៉ាន់ចេញពីសំពៅនាំព្រះអគ្គមហេសីយាងចូលទៅក្នុងព្រៃច្រកភ្នំ ហើយចតសំពៅនៅត្រង់កន្លែងនោះ។ ក្រោយពីស្តេច និងព្រះនាងព្រមទាំងព្រះរាជបរិវារឡើងគោកផុតភ្លាម ផ្ទៃមេឃក៏ងងឹត បណ្តាលឱ្យមានភ្លៀងផ្គរយ៉ាងខ្លាំង ស្រាប់តែរន្ទះបាញ់សំពៅក្រឡាប់លិចនៅទីនោះ។ ត្រង់កន្លែងនោះជាប់ឈ្មោះថា "ភ្នំរន្ទះ"។



As for the junk of the king Bayong, it went very fast to the southwest. The king saw a lot of islands and mountains so he anchored his junk near an island and walked up to the island to find a good place and build temporary residence. When he discovered that there were several favorite places, the king ordered his soldiers and servants to take all luggages out of the junk, took his wife into the valley of the mountain, and landed the junk there. After the king, the queen and all of his coordinates got out of the junk, the sky became dark and the rain was pouring so heavily. Suddenly, the thunderbolt struck the junk to overturn and sink. That place has been called Phnom Ronteah .



បន្ទាប់ពីនោះ **ស្តេចបាយ៉ង់** ចេះតែខំស្វែងរកទីភូមិឋាន ដើម្បីបានសង់ព្រះរាជដំណាក់ស្នាក់អាស្រ័យ។ គ្រានោះ ទ្រង់បានជួបទីទួលមួយខ្ពស់ល្អគួរជាទីរីករាយក្រៃពេក ក៏ទ្រង់ធ្វើព្រះពន្លាបណ្តោះអាសន្ននៅទីនោះ។ លុះស្តេចស្នាក់នៅបានស្រួលបួលហើយ ក៏ទ្រង់សំណេះសំណាលជាមួយព្រះអគ្គមហេសី អំពីសេចក្តីកំសត់ទុក្ខវេទនារបស់ព្រះអង្គ និងព្រះនាងតាំងពីដើមទីមក។ ព្រះនាងទ្រង់រំលឹកព្រះរាជាអំពីរឿងដែលទ្រង់បន់ថានឹងដាក់ព្រះកេសកោរសក់ថ្វាយអារក្សទឹកនោះ ពេលនេះព្រះអង្គត្រូវតែដាក់ព្រះកេសលាបំណន់ក្នុងវេលានេះឯង។ **ស្តេចបាយ៉ង់** ទ្រង់ក៏កោរព្រះកេសថ្វាយអារក្សទឹក ដូច្នេះបានជាជាប់នាមថា **ស្តេចបាយ៉ង់កោរ** ហើយដីទួលខ្ពស់ដែលទ្រង់ធ្វើព្រះពន្លានោះ ជាប់ឈ្មោះថា "ភ្នំបាយ៉ង់កោរ" រហូតមកដល់សព្វថ្ងៃ។ **ស្តេចបាយ៉ង់កោរ** ទ្រង់គង់នៅលើភ្នំនោះជាមួយ **ព្រះនាងសក់ក្រអូប** ជាព្រះអគ្គមហេសីបានសេចក្តីសុខជាង១ឆ្នាំ ព្រះអគ្គមហេសីទ្រង់ក៏មានព្រះគភ៌។

After that king Bayong kept looking for a place to build a royal residence. At that time, the king found a fascinating hill so he built a temporary shelter. When having a suitable residence, the king and the queen talked about their sadness and suffering from the beginning. The queen reminded the king of his praying that he would have his hair shaved for the water demons. Now the king had to fulfill his promise. King Bayong had his hair shaved for the offering for the water demons. That was why the king was called Bayong Kor and the hill, he built the shelter, has been called Bayong Kor Mountain. King Bayong Kor resided peacefully with his wife on the hill for over one year, and then the queen was pregnant.



លុះគ្រប់ទសមាស ទ្រង់ក៏ប្រសូតបានព្រះរាជបុត្រមួយអង្គ ព្រះនាមថា **ព្រះបាទដៃខ្លី** ។ ព្រះរាជបុត្រនេះពិតមែនតែមាននាម **ព្រះបាទដៃខ្លី** តែទ្រង់មានព្រះសិរីរាង្គអវយវៈពេញលក្ខណៈល្អទាំងអស់ ជាព្រះរាជកុមារក្លាហានអង់អាច រូបឆោមក៏ស្អាតសក្តិសមល្អឥតខ្ចោះ នាំឱ្យព្រះវរបិតា និងមាតា សព្វព្រះទ័យក្រៃលែង។ តាំងពី **ស្តេចបាយ៉ង់កោរ** និង **ព្រះនាងសក់ក្រអូប** ភៀសព្រះអង្គមកគង់នៅកោះនេះមក ពុំដែលមានលេចឮដំណឹងអំពីស្តេចសៀមបន្តិចសោះឡើយ ព្រះអង្គគង់បានសុខសប្បាយឥតមានទុក្ខភ័យនឹកនាដល់ស្តេចសៀមមកដល់ទីនេះឡើយ។

When it was due time, she delivered a baby namedPreahBath Daikley (short arms King). Though this prince was namedPreahBath Daikley but his body was normal and he was such a good-looking, clever boy that his parents were very satisfied with him. SincePreahBath Bayong Kor and Preah Neang Sak Kraob escaped to this island, they never heard about Siam king. King Bayong Kor lived peacefully and was never afraid that Siam king would arrive at this island.





ក្រោយមក ស្តេចសៀមក៏រកកលល្បិចដើម្បីយក **ព្រះនាងសក់ក្រអូប** ឱ្យទាល់តែបាន ក៏រៀបចំរោងល្ខោនដ៏ពិសេសនៅលើសំពៅ ហើយជ្រើសរើសយកពួកមន្ត្រីរាជការជាច្រើនរូបដែលឈ្លាសវៃក្នុងល្បិចស៊ើបការណ៍ផ្សេងៗ ព្រមទាំងរេហ៍ពលជាច្រើនទៀត បញ្ជូនសំពៅសំដៅទៅទិសទក្សិណ ដើម្បីស្វែងរក **ព្រះនាងសក់ក្រអូប** ម្តងទៀត។ ពួកមន្ត្រី ពួកល្ខោន ហើយនិងពួកទាហានទាំងអស់ គេបានពិភាក្សាគ្នាដឹងកិច្ចការជាស្រេចដោយគេយល់ថា **ស្តេចបាយ៉ង់កោរ** និង **ព្រះនាងសក់ក្រអូប** ប្រាកដជានៅក្នុងកោះមួយឯនាយសមុទ្រ គេក៏ចេញសំពៅជាច្រើនថ្ងៃច្រើនយប់សំដៅទៅដល់កោះនោះ ហើយក៏បោះយុថ្កាចតសំពៅនៅជិតឆ្នេរកោះ

ដែល **ស្តេចបាយ៉ង់កោរ** គង់ស្នាក់អាស្រ័យនៅចម្ងាយប្រមាណ១២សិន ប៉ុណ្ណោះ។ ត្រង់កោះដែលពួកសៀមចតសំពៅនោះជាប់ឈ្មោះថា "ជើងប្រជុំ" តមកដល់សព្វថ្ងៃគេហៅក្លាយមកជា "ជើងកញ្ជុំ"។

Later on, Siam king made a bad scheme to abduct Preah Neang Sak Kraob. He had a special theater built on a junk and sent many clever officials who were good at investigating and many other soldiers to the south to look for Preah Neang Sak Kraob again. The officials, performers, and soldiers made a discussion, estimating that King Bayong Kor and Preah Neang Sak Kraob must be living on an island of the ocean. They left for the island for many days and nights. When they reached there, they anchored their junk around five hundred meters from Bayong Kor's island. The place where Siams anchored their junk had been called Cheung Brachum, which has now been known as Cheung Kanhchum.



ឯពួកពលសេនាសៀម កាលដែលបានចតសំពៅបោះយុថ្កាស្រួលហើយ គេក៏ដាក់ឈើធ្វើជាស្ពាន តពីសំពៅរបស់គេមកភ្ជាប់នឹងកំពង់នៃកោះនោះ ហើយក៏តាំងរៀបពិធីលេងល្ខោននៅក្នុងសំពៅរាល់យប់។ មនុស្សប្រុសស្រី ដែលនៅលើកោះទាំងប៉ុន្មាន ដោយពុំដែលបានមើលអ្វីឱ្យសប្បាយសោះ នោះ ក៏នាំគ្នាទៅមើលល្ខោនយ៉ាងកុះករ ហើយបានទទួលបដិសណ្ឋារកិច្ច យ៉ាងប្រសើរអំពីពួកពលរាជការសៀម។ លុះលេងយូរៗទៅ សេចក្ដីសប្បាយរីករាយរបស់មនុស្សនៅលើកោះ ក៏កើតមានឡើងដោយសារ



សិល្បៈរបាំរបស់ស្តេចសៀម បណ្តាលឱ្យអ្នកកោះ និងពួកពលសៀមស្និទ្ធស្នាលគ្នាយ៉ាងប្រពៃ។ ចំណែកពួកសៀមខាងស៊ើបការណ៍ ក៏យកការណ៍បានយ៉ាងច្បាស់លាស់ថា **ស្តេចបាយ៉ង់កោរ** ពិតជាស្នាក់នៅក្នុងកោះនេះមែន។ អ្នកមើលល្ខោនទាំងប៉ុន្មាន កាលត្រឡប់ទៅផ្ទះវិញក៏នាំគ្នានិយាយអួតសរសើរអំពីស្រីរបាំ និងពួកល្ខោនដែលចេះរាំយ៉ាងទន់ភ្លន់ និងអំពីការរៀបចំទទួលភ្ញៀវយ៉ាងប្រសើររបស់ពួកគេ។ ឯពួកភីលៀង និងពួកពលសេនា **ស្តេចបាយ៉ង់កោរ** ដែលបានទៅមើលល្ខោនជាមួយអ្នកកោះនោះក៏នាំគ្នាមកក្រាបទូល **ស្តេចបាយ៉ង់កោរ** និង **ព្រះនាងសក់ក្រអូប** រៀងរាល់ថ្ងៃដែលបានទៅមើលល្ខោន។

After properly anchoring their trunk, Siams built a wooden bridge from the junk to the port. Then, they performed the play on the junk every night. All men and women had never seen any interesting performance, so they crowdedly went to see the play and were greeted warmly by those Siams. When they performed for longer time, people on the island felt very happy by the Siam performance so that these people and Siams had very close relationship. The Siam spies discovered that King Bayong Kor was really living on that island. When the audience returned home, they admired the female dancers and performers, who could dance beautifully, and their warm welcome. Ladies-in-waiting and soldiers of Bayong Kor told King Bayong Kor and Preah Neang Sak Kraob everyday they went to see the show.

ថ្ងៃមួយ ព្រះនាងអត់ទ្រាំនឹងសេចក្ដីសប្បាយរីករាយនេះពុំបាន ដោយពួកភីលៀងចេះតែក្រាបទូលញឹកញាប់ពេក ព្រះនាងក៏ក្រាបទូលព្រះស្វាមីចង់ទៅមើលល្ខោននឹងគេឱ្យបានឃើញម្ដង ព្រោះពួកភីលៀងនិយាយថាល្អមើលណាស់។ **ស្ដេចបាយ៉ង់កោរ** ក៏ទ្រង់នៅស្ងៀមមិននិយាយអ្វីទាំងអស់។



ព្រះនាងក៏ទុកព្រះរាជបុត្រឱ្យនៅជាមួយភីលៀងក្នុងព្រះរាជដំណាក់។ ព្រះនាងយាងចេញទៅស្រង់ទឹកនៅមាត់កំពង់ លុះស្រង់រួចហើយ ក៏ទ្រង់គ្រឿងអលង្ការមានបរិវារប្រុសស្រីជូនព្រះរាជដំណើរទៅទតល្ខោន។

One day, since she could not help going to the theater and her servants kept telling her about the performance, Preah Neang Sak Kraob asked her husband for permission to see the performance once because the servants told her that it was wonderful. The king said nothing. She left her baby with her servant; Preah Neang Sak Kraob went to bathe in the port. Then, she wore jewelry and the male and female servants accompanied her to see the performance.



លុះចូលទៅដល់ ពួកមន្ត្រីនិងសេនាសៀមបានឃើញក៏ស្គាល់ថា **ព្រះនាងសក់ក្រអូប** ជាមហេសី **ស្តេចបាយ៉ង់កោរ** ដែលពួកគេកំពុងតែស្វែងរកនោះ ឥឡូវព្រះនាងបានចូលក្នុងឧបាយកលរបស់គេហើយ ពួកគេក៏បានរៀបចំបដិសណ្ឋារកិច្ចយ៉ាងគួរសមចំពោះព្រះនាង និងបានរចនាអាសនៈយ៉ាងវិចិត្រសម្រាប់ព្រះនាង។ កាលព្រះនាងគង់បានស្រួលបួលហើយ គេក៏ប្រគំបទភ្លេងមួយយ៉ាងពិរោះឈ្មោះថា បទលោមនាង រួចគេប្រគំ បទជើតទៀតជាកិច្ចបើកឆាកល្ខោនរបស់គេជាលំដាប់ហូរហែ។

When they arrived in the theater, the Siam officials and soldiers realized Preah Neang Sak Kraob, the wife of King Bayong Kor, who they had been looking for. They greeted her warmly and prepared a good seat for her. After she sat comfortably, the concert started a song called Lom Neang (comforting her) and another song Cheut Teat in order to start the play.





អារម្មណ៍របស់ព្រះនាង បានជិតជាប់នៅក្នុងសាច់រឿង និងបទភ្លេងដ៏ពិរោះនៃតួអង្គល្ខោន។ ចំណែកពួកសៀមដែលគេបានរៀបចំរួចជាស្រេចនោះ គឺគេណាត់គ្នាជាចង្វាក់ស្គរ និងទំនុកច្រៀង។ សំពៅរបស់គេ គេចងខ្សែយុថ្កាមួយនៅទិសឦសាន្តចម្ងាយ ៦-៧ សិន សម្រាប់រវៃសំពៅថយ កន្លែងនោះជាប់ឈ្មោះថា "ភូមិយុថ្កា" លុះគេដឹងថា ព្រះនាងកំពុងតែជាប់ព្រះទ័យយ៉ាងមាំចំពោះសាច់រឿង និងបទភ្លេង គេក៏ប្រគំបទភ្លេងមួយហៅថា "បទស្រាវខ្សែយុថ្កា" ហើយគេក៏ប្រគំបទភ្លេងមួយទៀតឈ្មោះថា "បទសំពៅថយ" រួចគេចាប់រវៃខ្សែយុថ្កា ហើយសំពៅក៏ចេះតែថយចេញបន្តិចម្តងៗ។ ឯ **ព្រះនាងសក់ក្រអូប** ព្រមទាំងភីលៀងឥតដឹងថាសំពៅថយចេញសោះឡើយ កំពុងជក់ព្រះទ័យនឹងល្ខោននោះក្រៃលែង។ សំពៅក៏ថយចេញឆ្ងាយទៅៗ ទើបព្រះនាងនឹកចង់វិលមកព្រះរាជដំណាក់វិញ។

She deeply concentrated on the themes of the story and beautiful songs of the characters in the play. The Siams had already made the appointment with sound of drum rhythms and lyrics of songs. The junk was tied up to an anchor to the northeast about 300 meters to drag the trunk backward. The place which anchor was dropped has been called "Yuthkar village". When they knew that she was stuck up with the themes and music, they sang a song called Srav Khse Yuthkar (unfastening the rope of anchor). Then, another song called as Sampov Thoy (reverse the junk). Then, they untied the rope and the junk reversed gradually. Preah Neang Sak Kraob and her servants did not know that the junk was reversing and moving because they were focusing on the performance. While the junk was goimg further and further, Preah Neang Sak Kraob wanted to go home.





លុះទ្រង់ងាករកផ្លូវចាកអាសនៈល្ហែន ស្រាប់តែឃើញសុទ្ធតែទឹកល្ហល្ហាចរកកោះត្រើយមិនឃើញ ព្រះនាងក៏ស្រឡាំងកាំងភ័ន្តភាំងញ័រចំប្រប់កណ្ដាលមហាសាគរ។ ព្រះនាងទ្រង់នឹកឃើញដល់រឿងដើមកាលដែលរត់ពីភ្នំដងរែកដើម្បីឱ្យផុតពីកណ្ដាប់ដៃសៀម ឥឡូវគេចមិនផុត ត្រលប់ជាវិលមកចូលក្នុងឧបាយកលរបស់សៀមទៅវិញ ក៏ទ្រង់ព្រះកន្សែងដោយក្រៀមក្រំថា "ឱ! ថ្ងៃនេះហើយដែលខ្ញុំត្រូវព្រាត់ប្រាស់ពីស្វាមីកំសត់ និងបុត្រជាទីស្រឡាញ់"។ ឯពួកសៀម គេច្រានអស់ពួកភីលៀងរបស់ **ព្រះនាងសក់ក្រអូប** ឱ្យចុះក្បូនត្រលប់មកវិញ គេយកតែព្រះនាងមួយអង្គទៅតែប៉ុណ្ណោះ។ លុះពួកគេបានព្រះនាងហើយ ក៏នាំយកទៅថ្វាយស្ដេចសៀម។ ស្ដេចសៀមត្រេកអរណាស់ បានឱ្យរង្វាន់ខាន់ខោយ៉ាងច្រើនដល់ពលសេនាទាំងនោះ។ ស្ដេចសៀមបានយក **ព្រះនាងសក់ក្រអូប** មកគង់ក្នុងប្រាសាទដោយឡែក ហើយឱ្យពួកស្រីស្នំក្រមការនៅចាំបម្រើព្រះនាង។

When she turned her eyes to find the way home, she saw nothing but the vast water. She was shaking and shocked in the middle of the ocean. She remembered the past time when she left Dang Rek Mountain to run away from Siams, but now she could not escape and was abducted because of not knowing Siams' trick. She sobbed and said, "Oh! It is today that I am separated from my poor husband and my beloved son." Siams pushed her servants to return home by rafts; only Preah Neang Sak Kraob was taken. After abducting her, Siams took her to their king. Siam king was very happy. He awarded them many presents. He kept her in a separated castle and ordered his womenservants to serve her there.

ចំណែក **ស្តេចបាយ៉ង់គោរ** កាលបើទ្រង់ជ្រាបថាពួកពលសៀមនាំយកព្រះអគ្គមហេសីទៅហើយ ព្រះអង្គក៏កើតទុក្ខសោកសង្រេងក្រៃលែង មិនចង់ធ្វើអ្វីទាំងអស់ ទឹកព្រះនេត្រហូរជាប់ជានិច្ចទ្រាំរស់នៅជាមួយព្រះរាជបុត្រ។ ព្រះអង្គទ្រង់គង់គយគន់ទៅមហាសាគរ ស្ទើរតែបែកព្រះនេត្រ តែមិនបានឃើញអ្វីក្រៅពីទឹកដ៏ធំល្វឹងល្វើយ និងរលកបោកបែកផ្កាត្រែងនោះឡើយ ទ្រង់ងាកមកមើលលើកោះវិញ ក៏ទ្រង់ឃើញតែរុក្ខាលតាវល្លិដែលសុទ្ធតែជាធម្មជាតិរស់រវើក ហាក់ដូចជាចង់ជួយរំលែកនូវសេចក្តីទុក្ខរបស់ទ្រង់។ ព្រះអង្គមានព្រះបន្ទូលថា "កំសត់អើយ! កំសត់អ្វីម្ល៉េះ បងស្រណោះណាស់កាលបងនាំអូនរត់ផុតពីដៃសៀម ឥឡូវមិនផុតគង់ភ្លាត់ស្នៀតធ្វើឱ្យបងទីមទាមនៅម្នាក់ឯង"។

When king Bayong Kor knew that his wife was abducted, he was absolutely grief-stricken. His tear dropped every day, but he bore to live for his son. He looked at the ocean he nearly became blind. He saw nothing, but the vast water and waves of the sea. When he turned his eyes to the island, he saw the landscape and forest that seemed to help relieve his suffering. "How sad I am!" said the king, "I am nostalgic when you and I ran away from Siams. Now, it is not evitable to make a great mistake that leave me so lonely."



ចំណែក **ព្រះនាងសក់ក្រអូប** ដែលគង់នៅក្នុងប្រាសាទមួយតែព្រះអង្គនោះមានព្រះភក្ត្រស្រពាប់ស្រពោនជានិច្ច ទោះបីស្រីស្នំក្រមការខំយកចិត្តទុកដាក់បម្រើផ្គាប់ផ្គុនយ៉ាងណា ក៏មិនស្រាកស្រាន្តពីសេចក្តីទុក្ខដែរ ប្រាសាទធំល្វឹងល្វើយ តែហាក់ដូចជាចង្អៀតរកផ្លូវដើរគ្មាន។ មួយថ្ងៃៗ ព្រះនាងតែងគង់អើតតាមបង្អួចខាងត្បូងជានិច្ច សម្លឹងរកមើលក្រែងបានឃើញមនុស្សដែលព្រះនាងធ្លាប់ស្គាល់។ ស្តេចសៀម ឱ្យទាហានយាមទ្វារជានិច្ច មិនឱ្យព្រះនាងចេញទៅណាបានឡើយ ព្រះនាងកើតទុក្ខសោកសង្រេងរាល់ថ្ងៃនឹកឃើញព្រះរាជបុត្រតូចជាទីស្រលាញ់ និង ព្រះស្វាមីជាគូកំសត់។





Preah Neang Sak Kraob, who was staying alone in the castle, always felt very upset even though she was attentively served and pleased by the servants, she could not be relieved from the suffering. For her, though the castle was very big, but it seemed too narrow to find way to walk. Every day, she sat and looked out at the south window to look for anyone with whom she might be familiar. Siam king always ordered the soldiers to guard at the doors and would not let her out at all. She was very sad everyday because she missed her beloved son and her poor husband.



ច្រើនឆ្នាំក្រោយមក **ព្រះអង្គម្ចាស់ដៃខ្លី** ក៏មានវ័យវឌ្ឍនាការចំរើនធំឡើង សួរព្រះបិតារកព្រះមាតាដែលមិនបានឃើញទាល់តែសោះ។ **ស្តេចបាយ៉ង់កោរ** ក៏ប្រាប់ព្រះរាជបុត្រតាមដំណើររឿងគ្រប់យ៉ាង។ ព្រះអង្គក៏កើតសេចក្តីក្តៅក្រហាយជាខ្លាំង សូមលាព្រះបិតាទៅតាមរកព្រះមាតាយកមកវិញឱ្យទាល់តែបាន។ ព្រះបិតាក៏មានព្រះបន្ទូលថា "បើបុត្រទៅតាមរកព្រះមាតា បុត្រទៅដៃទទេពុំបានទេ ទោះបីបុត្រយកម្តាយមកវិញក៏នឹងប្រយុទ្ធគ្នាខាងផ្លូវសង្គ្រាមជាមិនខាន ដូច្នេះបុត្រកុំអាលទៅអី ចាំបិតាកេណ្ឌសេនារេហ៍ពលឱ្យបានទៅកំដរ បើមានអាសន្នមកដល់កូនអាចដោះខ្លួនបាន"។ ទើប **ស្តេចបាយ៉ង់កោរ** ទ្រង់ជ្រើសរើសមនុស្សដែលក្លាហាន ស្មោះត្រង់ចិត្តចូលធ្វើជាពលសេនា បានចំនួនរាប់ម៉ឺននាក់ឱ្យមកប្រជុំនៅកន្លែងមួយតាំងសីលមន្តវិជ្ជាការហាត់រៀនមន្តអាគមគាថានៅទីព្រះលានមួយ ទើបនៅទីនោះជាប់ឈ្មោះថា "ស្រែចមពល" រហូតមកដល់សព្វថ្ងៃនេះ។

Years later, prince Dai Kley became mature. He asked his father for his missing mother. King Bayong Kor, then, told his son about what had happened. The prince was furious. He asked for permission to look for and save his mother. The king said, "If you go alone with bare hand, you can't save your mother. When you bring your mother back, there will be fighting; so it is not the right time to go. Please wait until I mobilize enough soldiers to go with you. If you are in danger, they can help you escape." The king selected lots of brave and loyal soldiers to assemble at a particular place to learn fighting lessons and magic. That place has been called Sre Chorm Pol up to now, (field where brave, loyal soldiers were assembled).



លុះទ្រង់យល់ថា បានការល្មមជាទីទុកចិត្តហើយ ទើបទ្រង់ឱ្យ **ព្រះបាទដៃខ្លី** ជាព្រះរាជបុត្រ ចុះសំពៅទៅតាមផ្លូវជើងទឹក សំដៅទៅទិសពាយ័ព្យ អស់ពេលរវាងបីសប្តាហ៍ទើបទៅដល់ព្រំដែនសៀម។ **ព្រះអង្គម្ចាស់ដៃខ្លី** ក៏ចតសំពៅនៅកំពង់នៃកោះមួយ ដែលមានដែនដីជាប់នឹងព្រំប្រទល់សៀមល្មមឃាងចូលទៅស្រុកសៀមបាន។ ដូចបានពោលមកហើយថា **ព្រះអង្គម្ចាស់ដៃខ្លី** ពិតមែនមានព្រះនាមថា **ដៃខ្លី** តែព្រះអង្គមានព្រះហស្តល្អ មានព្រះរូបស្អាតសង្ហាគួរជាទីពិតពិលរមិលមើលនៃពួកស្រីៗក្រមុំ ព្រះអង្គបានផ្តាំពួកពលទាំងអស់ថា "សូមលោកចាំសំពៅនៅទីនេះចុះ យើងទៅតែម្នាក់ឯងបានហើយ មិនកំណត់ថា ថ្ងៃណានឹងមកវិញទេ លុះត្រាតែយើងបានសម្រេចតាមសេចក្តីប្រាថ្នា ទើបត្រលប់មកសំពៅវិញ"។ ព្រះអង្គក៏ធ្វើដំណើរទៅដល់ក្រុងសៀម ក្នុងព្រះទ័យចេះតែគិតបណ្តើរថា "បើសិនបានជួបនឹងព្រះមាតា ប្រហែលជាមិនស្គាល់ព្រះភក្ត្រលោកទេ ចំណែកព្រះមាតាវិញ ក៏ប្រហែលជាមិនស្គាល់ទូលព្រះបង្គំដែរ"។

When King Bayong Kor realized that the soldiers were strong enough, he let his son prince Dai Kley travel by junk toward the northwest. It took them three weeks to arrive at the Siam border. Prince Dai Kley anchored his junk at a port near an island, which was so close that he could go into Siam kingdom. As mentioned, though prince Dai Khley was named short arms (Dai Kley) but he, like other men, had normal arms and was very handsome and charming. He told his soldiers, "Wait for me here, in our junk, I will go alone. I don't know when I will be back; I will return after I attain my goal." He continued his journey to his Siam city thinking, "If I meet my mother, she may not be able to recognize me, and neither may I."

គាប់ជួនជាថ្ងៃមួយ **ព្រះបាទដៃខ្លី** កំពុងតែសម្លឹងមើលនាយមើលអាយ ស្រាប់តែបានជួបប្រទះ **ព្រះនាងសក់ក្រអូប** ជាព្រះមាតាដែលគង់ត្រង់បង្អួចប្រាសាទ ទតមើលមកខាងក្រៅតែមួយព្រះអង្គឯង តែទ្រង់មិនស្គាល់ជាព្រះមាតាសោះ ទ្រង់គិតថា ជាស្រីសៀមមានរូបឆោមស្អាតស្រស់បំព្រង មុខមូលក្រឡង់ដូចវង់ចន្ទ បបូរមាត់ក្រហមឆ្អៅគួរជាទីស្រលាញ់ ក៏មានចិត្តប្រតិព័ទ្ធ ក៏ទ្រង់ពោលពាក្យបញ្ចិតបញ្ចៀងផ្តោះផ្តងឱ្យព្រះនាងដោយសេចក្តីស្នេហា។ ឯ **ព្រះនាងសក់ក្រអូប** វិញ មិនស្គាល់ថាប្រុសម្នាក់នេះជាព្រះរាជបុត្ររបស់ទ្រង់ឡើយ គិតថាជាប្រុសសៀមសុទ្ធសាធ ក៏កើតចិត្តប្រតិព័ទ្ធយ៉ាងខ្លាំង រហូតដល់បានពោលពាក្យសម្តីចែចង់តាមធម្មតារបស់ស្ត្រី និងបុរស។ ព្រះនាងបានផ្តាំព្រះអង្គថា ដល់ពេលព្រលប់ធំចាំឱ្យព្រះអង្គមកម្តងទៀត ព្រះនាងនឹងចុះពីប្រាសាទមកចាំផ្លូវ។ ព្រះនាងបានបញ្ជាក់ទៀតថា "ទីនេះស្ងាត់ល្អណាស់ ឥតមានមនុស្សចេញចូលញឹកញាប់ទេ"។ ព្រះអង្គម្ចាស់មានសេចក្តីស្នេហាជាខ្លាំង ហើយទ្រង់គិតថា "អញចង់កូនក្រមុំសៀមនេះឱ្យបានហើយ នឹងពង្រាត់យកនាងទៅទុកនៅសំពៅសិន សឹមដើរទៅរកម្តាយបន្តទៅទៀត"។ លុះដល់ពេលព្រលប់ធំ ព្រះអង្គម្ចាស់នោះ ក៏ត្រឡប់មកប្រាសាទវិញតាមបណ្តាំព្រះនាង។ ព្រះនាងក៏ចេញមកជួបនាំគ្នាឡើងទៅព្រះរាជដំណាក់។ អ្នកទាំងពីរក៏និយាយសំណេះសំណាលលួងលោមគ្នាដោយសេចក្តីស្នេហា បានប្រព្រឹត្តិស្ទន់អន្ទករនឹងគ្នា ហើយក៏នាំគ្នារត់ចេញពីព្រះដំណាក់សំដៅទៅកំពង់ជាទីចតសំពៅ។





One day, when the prince was looking around, he glanced at his mother Preah Neang Sak Kraob, who was sitting at the window alone looking outside. He did not know she was his mother. The prince thought, "This Siam lady is really beautiful, her face is as round as the moon, and she had so lovely red lips." He suddenly fell in love with her. He tried to pay a court to her. Preah Neang Sak Kraob, not recognizing the young man as her son, thought that he was a typical Siam man and courted him, too and they fell in love with each other. She told the prince, "Please come here again in the late night. I will go down and wait for you." She confirmed, " Here is very quiet; no one comes often." The prince had deeply fallen in love. He thought himself, "I will make love with this Siam girl and take her to the junk; then, I will be back to look for my mother." When the late night came, he returned to the castle as she told him. She went down to take him to her room. They made love and slept together. After that, they left for the prince junk.

លុះមកដល់សំពៅ ព្រះនាងស្គាល់អាមាត្យជាក្រុមញាតិជាអ្នកបម្រើ អ្នកទាំងនោះក៏ភ្ញាក់ខ្លួន ហើយសាកសួរគ្នាទៅវិញទៅមកភ្លាម ក៏ដឹងច្បាស់ថាស្ត្រីនេះជា **ព្រះនាងសក់ក្រអូប** ជាព្រះមាតារបស់ **ព្រះអង្គម្ចាស់ជៃខ្លី** ជាព្រះរាជបុត្រ។ ព្រះនាងក៏ជ្រាបថា បុរសនេះជាព្រះរាជបុត្រជាទីកំសត់ ដែលព្រះនាងប្រាសចាកចោលមកអស់រយៈកាលជាង១០ឆ្នាំមកហើយ។ ព្រះមាតា និងព្រះរាជបុត្រក៏ឃំឱបគ្នាដោយសេចក្ដីនឹករលឹកយ៉ាងសែនកំសត់។ ឯសេចក្ដីស្នេហាដោយតណ្ហា ក៏រលាយបាត់ក្នុងពេលនោះគ្មានសល់។ ព្រះរាជបុត្រ ក៏មានសេចក្ដីរន្ធត់ញាប់ញ័រជាពន្លឹកចំពោះអំពើពុំគប្បី ដែលទ្រង់បានធ្វើចំពោះព្រះមាតា ទោះជាព្រះមាតាអត់ទោសយ៉ាងណា ក៏មិនស្ងប់សេចក្ដីញាប់ញ័រនោះឡើយ។ ពួកពលសេនា កាលបានព្រះនាងហើយ ក៏នាំគ្នាបើកសំពៅយ៉ាងលឿនឥតមានបង្អង់ ឆ្ពោះទៅកាន់ព្រះរាជដំណាក់ **ព្រះបាទបាយ៉ង់កោរ** វិញ។

When they got at the junk, she recognized Banyong Kor's soldiers and relatives. They talked to each other and knew that she was Preah Neang Sak Kraob, the prince's mother. She was informed that the young man was her son that she left for over ten years. The mother and son embraced each other because of missing, and their love relationship was disappeared. The prince was deeply shocked by his misconduct toward his mother. Even though his mother apologized for him, he could not get rid of this shock. The soldiers, when finding Preah Neang Sak Kraob, quickly sailed the junk as fast as they could toward Bayong Kor's palace.





បីសប្ដាហ៍ក្រោយមក សំពៅក៏បានមកដល់ព្រះរាជដំណាក់។ **ស្ដេចបាយ៉ង់កោរ** និង **ព្រះនាងសក់ក្រអូប** បានមកជួបជុំគ្នាដោយសេចក្ដីរីករាយ និងដោយសេចក្ដីសោកសង្រេងទង្គឹះខ្សឹកខ្សួលព្រោះសេចក្ដីនឹករលឹកបំផុត។ កាលបើបានជួបព្រះភស្ដាជាទីស្រលាញ់ហើយ ព្រះនាងក៏ក្រាបបង្គំទូលរៀបរាប់តាមដំណើរថា "គេនាំយកខ្ញុំម្ចាស់ទៅឱ្យនៅក្នុងប្រាសាទមួយតែម្នាក់ឯង មានពួកស្រីៗនៅកំដរចាំបម្រើគ្រប់ពេលវេលា គ្មានស្ដេចសៀមរឺកំលោះណាមកបៀតបៀនខ្ញុំម្ចាស់ទេ។ ពេលដែលកូនយើងទៅដល់ ខ្ញុំម្ចាស់មិនស្គាល់ជាកូនរបស់យើងសោះ នឹកស្មានថាជាប្រុសកម្លោះមកពីណា។ ចំណែកកូនយើងវិញ ក៏មិនស្គាល់ខ្ញុំម្ចាស់ជាម្ដាយដែរ។ ពេលបានជួបគ្នា ក៏កើតចិត្តប្រតិព័ទ្ធស្នេហារហូតដល់បានស្ម័គ្រស្នន់អន្ទករជាមួយនឹងកូនរបស់យើងនេះទៅហើយ សូមព្រះស្វាមីអភ័យទោសដល់រូបខ្ញុំម្ចាស់ ព្រមទាំងបុត្រផង"។

Three weeks later, the junk reached the palace. King Bayong Kor and Preah neang Sak Kraob were reunited happily, excitedly and they sobbed because they missed each other so much. When Preah neang Sak Kraob met her beloved husband, she told him, "I was kept in the castle alone with many women-servants all day and night, and no one bothered me, even Siam King. When our son came there, I did not recognize him, and neither did our son. We both fell in love and engaged in sexual intercourse. Please apologize me and our son."



**ស្តេចបាយ៉ង់កោរ** ទ្រង់ជ្រាបហេតុសព្វគ្រប់តាមពាក្យទូលនៃព្រះនាង ហើយ ទ្រង់ក៏ឥតមានខ្វាល់អ្វីឡើយ ដោយព្រះអង្គទ្រង់ពិចារណាថា "ធម្មតាម្តាយនិងកូន ទោះបីយ៉ាងណាក៏មិនហ៊ានប្រព្រឹត្តិអំពើពុំគប្បីយ៉ាង នេះដែរ នេះគឺមកពីហេតុមិនស្គាល់គ្នាបានជាហ៊ានប្រព្រឹត្តិអនាចារយ៉ាង នេះ"។ រឿងនេះ **ស្តេចបាយ៉ង់កោរ** ព្រះអង្គមានសន្ទិះសង្ស័យក្រែងលោ ព្រះរាជបុត្រមានបាបកម្មធ្ងន់ធ្លាក់ដល់អបាយ ទើបព្រះអង្គ ឱ្យហៅអ្នកប្រាជ្ញ រាជបណ្ឌិតកវីហោរា មកជួបជុំពិគ្រោះគ្នាមើល ក្រែងមានកម្មពៀរវេរាទៅ ជាតិខាងមុខ។ លុះជំនុំពិគ្រោះធៀបមើលហេតុផលសព្វគ្រប់ទៅ ក៏បាន វិនិច្ឆ័យសម្រេចថា "ត្រូវតែឱ្យព្រះរាជបុត្រទទួលទណ្ឌកម្ម គឺត្រូវជីកស្រះ ឱ្យបានចំនួន១០០១អង្គ"។ **ស្តេចបាយ៉ង់កោរ** ក៏ទ្រង់ចាត់ឱ្យពលករ១០០១ នាក់ ឱ្យជួយជីកស្រះព្រះរាជបុត្រដែរ។

After listening to what she told, the king was not angry because he thought, "Never have son and mother made love with each other; this was because they did not know each other, they made a great mistake." Since King Bayong Kor was afraid that his son would be sinful, he called for scholars and prophesiers to prophesy whether his son would have a sin or not. Through a long analytical discussion, they decided, "The prince has to be punished to dig up 1001 ponds (1001 Sreas Ang)." Then, the king decided to order the laborers help him.



លុះជីករួចកើតបានជាស្រះហើយ ក៏ទ្រង់ចាត់ចែងធ្វើបុណ្យឆ្លង ហើយព្រះរាជបុត្រទ្រង់អធិដ្ឋានថា "ស្រះអង្គទាំង១០០១ ដែលជាស្នាដៃខ្ញុំកសាងនេះ ខ្ញុំសូមឧទ្ទិសទុកជាប្រយោជន៍ដល់សត្វនិករ ដើម្បីនឹងបានទឹកប្រើតទៅ ដរាបណាស្រះអង្គនេះលែងដក់ទឹក ហើយដីដុះរាបស្មើឡើងវិញដូចធម្មតា ដរាបនោះ សូមឱ្យទោសរបស់ខ្ញុំរលាយអហោសិកម្មទៅ"។ ហេតុនេះហើយបានជានៅក្នុងខេត្តតាកែវទាំងមូល មានទីកន្លែងដែលមានឈ្មោះថាអង្គៗច្រើនណាស់ ដូចជា អង្គរកា អង្គសិង្ហ ជាដើម។ **ចប់**

**"ការឈឺចាប់នូវអ្វីមួយដែលធ្វើខុស ជាមេរៀនសម្រាប់ជៀសវាងទៅថ្ងៃក្រោយ"**

After the 1001 ponds were dug up, the king celebrated a religious ceremony for the completion, The prince wished, "Now I have dug up 1001 ponds, I would devote these ponds for the advantage of all living creatures on earth to use the water from today onwards until all the ponds become dry and the soil comes up as flat as normality, then my sin will be vanished." Thus there have been many places named Angs namely Ang Rokar, Ang Soeng and so on. **The End**

**Failures are good lessons for us to learn.**